ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៨១/២៤ គ.ជ.ប.ជ

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# ប្រចាំខែមីនា និងទិសដៅខែមេសា ឆ្នាំ២០២៤

## I. ស្ថានភាពទូទៅ

សភាពការណ៍សកលលោកបានប្រឈមនឹងវិបត្តិសាកលធំៗ ប្លែកៗ គួរឱ្យកត់សម្គាល់ រួមទាំងគ្រោះធម្មជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ជម្ងឺរាតត្បាត វិបត្តិខ្វះស្បៀងអាហារ សង្គ្រាមរ៉ាំរ៉ៃដែលបាន និងកំពុងគម្រាមកំហែងដល់សន្តិសុខមនុស្សជាតិ តាមបណ្តាប្រទេសដែលមានខឿនឧស្សាហកម្មជឿនលឿនមួយចំនួនបានជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមជាសកល គួរឱ្យព្រួយបារម្ភ ដែលវិបត្តិនេះ ក៏បានជះឥទ្ធិពលដល់បណ្តាប្រទេសនានា រួមទាំងកម្ពុជាផងដែរ។ ក្នុងស្ថានភាពដ៏លំបាកនេះ ប្រជាពលរដ្ឋ តាមបណ្តាប្រទេសនានាបានប្រឈមនឹងកង្វល់យ៉ាងធ្ងន់ធ្ងរនៃអសន្តិសុខ ក៏ដូចជាភាពស្មុគ្រស្មាញក្នុងជីវភាពរស់នៅ ដែលជាឱកាសឱ្យក្រុមទុច្ចរិតបានប្រើគ្រប់មធ្យោបាយទាញយកផលចំណេញ តាមរយៈការបង្កើតនូវបទល្មើសថ្មីៗ រួមទាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ ជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដ៏ទំនើប ទាក់ទាញមនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ស្ថានភាព ឱ្យរងគ្រោះ ក្នុងកលល្បិចដ៏ពិសពុលដើម្បីបម្រើមហិច្ឆតាផលប្រយោជន៍ទុច្ចរិតរបស់ខ្លួនយ៉ាងសាហាវឃោរឃៅ។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយបង្កើតនូវបទល្មើសថ្មីៗ នៃទាសភាពសម័យទំនើប និងលេចឡើងនូវការកេងប្រវ័ញ្ច និងរំលោភបំពានតាមប្រព័ន្ធអនឡាញ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះ និងជនងាយរងគ្រោះ។

រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧នៃរដ្ឋសភា បានបន្តការប្តេជ្ញាចិត្ត យកចិត្តទុកដាក់យ៉ាងខ្លាំងលើកិច្ចការពារថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ សុខសុវត្ថិភាពនិងសុខុមាលភាពសង្គមឱ្យបានរឹងមាំ ព្រមទាំងការធានានូវសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញនិងបទបញ្ញត្តិច្បាប់ជាធរមាន។ ឯនៅក្នុងតំបន់ ខិតខំដោះស្រាយបញ្ហា ដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ។

ជាការឆ្លើយតបចំពោះការប្តេជ្ញាចិត្តខ្ពស់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាលអាណត្តិថ្មី បានដាក់ចេញនូវយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ មុំទី១ (ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ - អទិភាពទី៤) និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាសេនាធិការ ជូនរាជរដ្ឋាភិបាល ក៏បានការកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនផងដែរចាប់ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងរៀបចំផែនការយុទ្ធសាស្រ្តជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ(២០២៤-២០២៨)។

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១.៧៨៨ | ៨៧.១៩៨ | ៤២.៧៨៨ | ៧៦៤ | ៣១.៧៧៤ | ១៦.៧៩៥ |
| សរុប ក្រសួង ស្ថាប័ន | | ១.៧៨៨លើក | ៨៧.១៩៨នាក់ | ៤២.៧៨៨នាក់ | ៧៦៤លើក | ៣១.៧៧៤នាក់ | ១៦.៧៩៥នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ១.៤០៩ | ៩៥.០៦៥ | ៤៦.៨០៦ | ១.៣៥៧ | ៥២.៩៥៦ | ២៦.៣៧២ |
| ៣ | ខេត្តបាត់ដំបង | ៩៦៧ | ៤៧.៥៧៨ | ២៤.៧៦២ | ៧៣០ | ២៤.០៩៤ | ១១.៩៩១ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៥៧ | ៣១៦.០៦៩ | ១៥.៣០៦ | ១៩៨ | ៩.៣៣៦ | ៤.៧៤៧ |
| ៥ | ខេត្តសៀមរាប | ៤៨១ | ៣៧.០៩៥ | ២៣.០៤០ | ២៧៦ | ៨.៣១១ | ៦.៥១៦ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧១៧ | ២២.៣០១ | ១១.៦៦៦ | ៣៧២ | ៥.៩០៤ | ៥.៦៥៧ |
| ៧ | ខេត្តកំពង់ចាម | ១.៧០៨ | ៩២.៤០៧ | ៤៧.៦៤៩ | | | |
| ៨ | ខេត្តព្រះសីហនុ | ១១៧ | ៣.២៧១ | ២.៦៤៩ | | | |
| ៩ | ខេត្តព្រះវិហារ | ១៤ | ១.៥៦០ | ៨១៩ | | | |
| ១០ | ខេត្តស្វាយរៀង | ៣២១ | ២៣.១២៣ | ៩.៨០០ | ២០១ | ៩.៧៨៨ | ៥.៤១៦ |
| ១១ | ខេត្តប៉ៃលិន | ៨ | ៤.១៤៥ | ២.២៦៥ | ៤៩ | ១.៤៣៥ | ៦៦៣ |
| ១២ | ខេត្តកោះកុង | ៣៣៩ | ៨.៩៦៨ | ៤.៣៤៥ | ១៤៨ | ៣.៣០៦ | ១.៦៦៤ |
| ១៣ | ខេត្តកំពត | ៣១ | ៦០១ | ២៨៨ | ១៥ | ៥៦០ | ៣៥០ |
| ១៤ | ខេត្តកំពង់ធំ | ៣៤៩ | ២១.៨៨០ | ១២.៤៦៥ | ៧៦ | ៣.៤២៦ | ១.៨១៩ |
| ១៥ | ខេត្តតាកែវ | ៦៤៣ | ៣៣.៣០៨ | ១១.៩៨២ | ១១៩ | ២.៩៦៤ | ១.៤៥២ |
| ១៦ | ខេត្តក្រចេះ | ២២ | ២.៣៦៤ | ១,១៧៨ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | ៧ | ៧.៧៧៤ | ៤.១៣៩ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ១០ | ៦៩៣ | ៤៤៦ | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ៨៥០ | ៤៦.៥២៦ | ២៤.៣៩៦ | ៣៦៧ | ១២.៣៣៣ | ៦.១១៨ |
| ២២ | ខេត្តត្បូងឃ្មុំ | ២១០ | ៣.៤៩២ | ២.០៨០ | ៦ | ១៧៨ | ៨០ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៩៤២ | ១៤.៣៣១ | ៨.២១២ | ១៧៨ | ៥.២១៥ | ៣.០៧៧ |
| ២៤ | ខេត្តឧត្តរមានជ័យ | ២២៩ | ១៦.៨៥៤ | ៩.៧១០ | ៤៧ | ១.៦១០ | ១.១៤៥ |
| ២៥ | ខេត្តមណ្ឌលគិរី | ២៤៦ | ៧.៦៤៦ | ៣.៥៦៧ | ២៣ | ៧៦៥ | ៣៦៧ |
| សរុប រាជធានី-ខេត្ត | | ៩.៩៧៧លើក | ៨០៧.៧២០នាក់ | ២៦៧.៥៧០នាក់ | ៤.១៦២លើក | ១៤២.១៨១នាក់ | ៧៧.៤៣៤នាក់ |
| សរុបរួម | | ១៦.៦៩១ លើក | | ១.០៦៨.២០៤ នាក់ | | ៤០៤.៥៨៧ នាក់ | |

### ១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសន្និបាតផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ មានវត្តមានអញ្ជើញចូលរួមក្នុង

អង្គពិធីមាន ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នជាប្រធាន និងអនុប្រធាន សមាជិក នៃក្រុមការងារអន្តរក្រសួងទាំង៦ នៃ គ.ជ.ប.ជ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរងជាប្រធាន គ.ខ.ប.ជ និងប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ រាជធានី-ខេត្តទាំង២៥ លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត កុងស៊ុល និងតំណាងបេសកកម្មនៃបណ្តាប្រទេសជាមិត្តប្រចាំនៅកម្ពុជា តំណាងអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល សរុបចំនួន **៣៩២**នាក់(ស្រី**១៥៨**នាក់) ។

- **ខេត្តកណ្តាល៖** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបការផ្សព្វផ្សាយការបង្ការទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងពិធីសន្និបាតបូកសរុបវាយតម្លៃការងារ អប់រំ យុវជន និងកីឡា ឆ្នាំ២០២២-២០២៣ និងផ្សព្វផ្សាយជូនមន្ត្រីរាជការមន្ទីរអប់រំ យុវជន និងកីឡា មន្ត្រីជាប់កិច្ចសន្យារៀងរាល់ព្រឹកថ្ងៃចន្ទ គោរពទង់ជាតិចំនួន **០៥**លើក អ្នកចូលរួម **៤៣៦**នាក់(ស្រី**១២៧**នាក់)។

- **ខេត្តកំពង់ឆ្នាំង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះផ្សព្វផ្សាយ និងតាមដានការអនុវត្តសេចក្តីណែនាំលេខ១៤៧/២១ ស.ណ.ន របស់រដ្ឋបាលខេត្តស្តីពី ការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងបានផ្សព្វផ្សាយការជួញដូរ ការកេងប្រវ័ញ្ចកម្លាំងពលកម្មស្ត្រីនិងកុមារ និងការធ្វើចំណាកស្រុកដោយខុសច្បាប់ នៅតាមរោងចក្រសហគ្រាស ចំនួន០២លើក មានកម្មករ និយោជិតចូលរួមចំនួន **១៦**នាក់(ស្រី**១០**នាក់)។

- **ខេត្តបាត់ដំបង៖ អង្គការសោម៉ារីតាន់កឹស** ១.បានធ្វើយុទ្ធនាការសម្តែងរឿងអប់រំខ្លី ដល់យុវជន អាណាព្យាបាល និងសហគមន៍ ស្តីពី ការចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការជួញដូរមនុស្ស អំពើហិង្សាលើយេនឌ័រ បាន ២ភូមិ មានអ្នកចូលរួម ចំនួន **២០០**នាក់។ ២.បានធ្វើយុទ្ធនាការប្រមូលយុវជនលេងកីឡាដើម្បីបញ្ជ្រៀបសារអប់រំពីការចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការជួញដូរមនុស្ស អំពើហិង្សា នៅភូមិស្មើ ឃុំជ្រៃសីមា អ្នកចូលរួម **៦៤**នាក់(ស្រី**១២**នាក់)។ ៣.អ្នកស្ម័គ្រចិត្តភូមិ និងយុវជនស្ម័គ្រចិត្តបានចុះផ្សព្វផ្សាយបន្តនូវមេរៀនពីការចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការជួញដូរមនុស្ស និងអំពើហិង្សាទាក់ទងនឹងយេនឌ័រតាមខ្នងផ្ទះ និងយុវជនតាមសាលារៀន អ្នកចូលរួម **១.២៨០**នាក់(ស្រី**៥៤៧**នាក់ អនីតិជន**៣៦៥**នាក់)។

- **ខេត្តសៀមរាប៖ មន្ទីរអប់រំយុវជន និងកីឡាខេត្ត** បានធ្វើការបញ្ជ្រាបការផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅក្នុងវគ្គបំប៉នស្តីពី ការពង្រឹងក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងគណៈកម្មាធិការប្រតិបត្តិ បានចំនួន ០៣លើក នៅវិទ្យាល័យអង្គរ វិទ្យាល័យ១០មករា និងវិទ្យាល័យសម្តេចឪ មានអ្នកចូលរួមសរុប**១០៥**នាក់(ស្រី**៥៩**នាក់)។

- **ខេត្តតាកែវ៖** ១.លោកស្រី **គា សុភូ** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានចូលរួមជាមួយក្នុងកម្មវិធីសំណេះសំណាលជាមួយបងប្អូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្នុងពិធីអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ "ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល" ក្នុងនោះក៏បានបញ្ជ្រាបការជួញដូរមនុស្ស និងការធ្វើចំណាកស្រុក ស្ថិតក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **អ៊ូច ភា** អភិបាលខេត្ត កម្មវិធីនេះមានអ្នកចូលរួមសរុបចំនួន **៧២**នាក់។ **២**.ឯកឧត្តមអភិបាលខេត្ត និងអភិបាលរងខេត្ត បានដឹកនាំកិច្ចប្រជុំ ពិភាក្សាការងារប្រចាំថ្ងៃ និងចូលរួមសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (តាមប្រព័ន្ធអនឡាញ) និងអញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ មេប៉ុស្តិ៍ នាយកសាលា និងប្រធានមណ្ឌលសុខភាព និងបានបញ្ជ្រាបការងារប្រឆាំងការជួញដូរមនុស្ស នៅតាមក្រុង ស្រុក សរុបចំនួន **៧៦**លើក មានអ្នកចូលរួមសរុបចំនួន **១.៥៧០**នាក់(ស្រី**៨៦៩**នាក់)។

- **ខេត្តកំពង់ស្ពឺ៖** ផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំ គ.ក.ស.ក ០៤លើក និងក្នុងកិច្ចប្រជុំ គ.ក.ន.ក ឃុំ **២៦**លើក មានអ្នកចូលរួមសរុប **៣៥០**នាក់(ស្រី**១៩៩**នាក់)។
- **ខេត្តប៉ៃលិន៖ ប្រធានមន្ទីរ អប់រំ យុវជន និងកីឡា** បានផ្សព្វផ្សាយអំពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធអនឡាញ ការធ្វើចំណាកស្រុក ក្នុងកិច្ចប្រជុំរបស់គណៈគ្រប់គ្រងសាលារៀន នៅអនុវិទ្យាល័យភ្នំយ៉ាត និងវិទ្យាល័យ ហ៊ុន សែន ក្រុងទេពនិម្មិតប៉ៃលិន និងពេលចុះពិនិត្យសកម្មភាពបង្រៀននិងរៀនសិស្សថ្នាក់ទី១២ មានអ្នកចូលរួម **៣០០**នាក់(ស្រី**២៧០**នាក់)។

**១.១.៣. ការផ្សព្វផ្សាយរបស់អង្គការដៃគូ**

- **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស** បានធ្វើយុទ្ធនាការអប់រំដល់អាណាព្យាបាលរបស់យុវជន និងសហគមន៍ ស្តីពីការចំណាកស្រុកដោយសុវត្ថិភាព ទប់ស្កាត់ការជួញដូរមនុស្ស និងការទប់ស្កាត់អំពើហិង្សា បាន០២ភូមិ គឺភូមិក្បាលថ្នល់ និងប្រឡាយប្រាក់ ឃុំអង្គរបាន អ្នកចូលរួម **១៥១**នាក់(ស្រី**១៤០**នាក់)។
- **ខេត្តសៀមរាប៖ អង្គការមូលនិធិអេ២១** បានធ្វើការអប់រំផ្សព្វផ្សាយបង្ការទប់ស្កាត់ស្តីពី អំពើជួញដូរមនុស្ស និងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញនៅតាមសហគមន៍ បានចំនួន **០២លើក** ដែលមានអ្នកចូលរួមសរុប **២២៥**នាក់(ស្រី**១៥០**នាក់)។
- **ខេត្តបន្ទាយមានជ័យ៖**
  - **អង្គការតំណក់ទឹក** បានចុះធ្វើសកម្មភាពបណ្ណាល័យចល័ត អប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន **០១**លើក អ្នកចូលរួម **៥៩**នាក់(ស្រី**៣៣**នាក់)។
  - **អង្គការសាម៉ារីតាន់ភឺស** បានអប់រំសហគមន៍អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករចំនួន **១.១៩០**នាក់(ស្រី**៥៩១**នាក់ អនីតិជន **០៩**នាក់)។

**១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកចូលទស្សនាចំនួន **១.៦២០**ដង។
- **ខេត្តត្បូងឃ្មុំ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុជាតិ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន **៦០**លើក។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយតាមវិទ្យុនគរភ្នំ និងទូរទស្សន៍ជាតិ ស្តីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារធ្វើក្នុងស្រុក ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិលចំនួន **២១៥**លើក។
- **ខេត្តប៉ៃលិន៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន **២៤៨**លើក។
- **ខេត្តព្រៃវែង៖ មន្ទីរព័ត៌មាន** បានផ្សព្វផ្សាយសារអប់រំ នៃការជួញដូរមនុស្ស តាមវិទ្យុបាវយណ៍អណ្តែត បានចំនួន **៥០**លើក។

**១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **ខេត្តកំពង់ចាម៖** តំណាងស្នងការនគរបាល បានចូលរួមជាវាគ្មិននៅវិទ្យុ **០២**លើក៖ **១**-ស្តីពីការទប់ស្កាត់ភាពមិនប្រក្រតី របស់យុវជនក្នុងទិវាបុណ្យនៃក្តីស្រឡាញ់។ **២**-ប្រសិទ្ធភាពនៃការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់។

### ១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ (IEC)

- **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស** បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព **១,៧៧០**សន្លឹក និងខិត្តប័ណ្ណអប់រំពីការពារការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ ចំនួន **៥៧២**សន្លឹក។

- **ខេត្តសៀមរាប៖** រដ្ឋបាលស្រុកពួក បានធ្វើការចែកខិតប័ណ្ណព័ត៌មាន ស្តីពីការធ្វើចំណាកស្រុក និងការស្វែងរកជំនួយចំនួន **៦.៣២២**ខិតប័ណ្ណ។

- **ខេត្តបន្ទាយមានជ័យ៖**
  - លេខាធិការដ្ឋាន គ.ខ.ប.ជ បានចងបដាពាក្យស្លោកទាក់នងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **០៦**ផ្ទាំង នៅសួនសាធារណៈ(សួនតេជោឈ្នះឈ្នះខេត្តបន្ទាយមានជ័យ)។
  - អង្គការសាម៉ារីតាន់ភឺស បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ ចំនួន **៩៧៨**នាក់(ស្រី**៤៣៩**នាក់ អនីតិជន**៥១**នាក់)។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងជាប់ការទាក់ទងសរុបចំនួន **១៩៣.៩៥៨**នាក់(ស្រី **៨៥.៨១២**នាក់) អនីតិជន **៣.១៣៨**នាក់(ស្រី **១.១៥១**នាក់)៖
  - ស្របច្បាប់ **១៥១.២៧២**នាក់(ស្រី **៦៨.៩៥៥**នាក់) អនីតិជន **៤២៦**នាក់(ស្រី **១៥៦**នាក់)។
  - មិនស្របច្បាប់ **៤២.០២១**នាក់(ស្រី **១៦.៥៧២**នាក់)អនីតិជន**២.៥៨២**នាក់(ស្រី **៩៦០**នាក់)។
  - ជាប់ការទាក់ទង **៦៦៥**នាក់(ស្រី **២៨៥**នាក់) អនីតិជន **១៣០**នាក់(ស្រី **៣៥**នាក់)។

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **១៩.១៧៩**នាក់(ស្រី **៧.៩២៩**នាក់) អនីតិជន **២៦០**នាក់(ស្រី **៩៤**នាក់)។

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន០២លើក មនុស្ស០៤នាក់(ស្រី០១នាក់ អនីតិជន០១នាក់)។

### ២.២. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ខេត្តត្បូងឃ្មុំ៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ក្រុមការងារអធិការកិច្ច បានចុះពិនិត្យបែបបទសហគ្រាស និងការអនុវត្តលក្ខខណ្ឌការងារនៅ ក្រុមហ៊ុន ហ្គ័រ-ស៊ីង ផ្លាយវូត និងក្រុមហ៊ុន ជីអិកស៍ ប្រាកជីខលផ្លាយវូដ ឯ.ក ឆ្លៀតឱកាសក្នុងពេលនោះក្រុមការងារអធិការកិច្ចបានផ្សព្វផ្សាយបន្ថែមស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានធ្វើបទបង្ហាញស្តីពី ការចំណាកស្រុក និងយន្តការដោះស្រាយវិវាទពលករទេសន្តប្រវេសន៍នៅសាលាស្រុកមេមត់ មានអ្នកចូលរួមសរុប **១២៧**នាក់(ស្រី**៧៩**នាក់) រៀបចំឡើងដោយ អង្គការសម្ព័ន្ធចាប់ដៃ។

### ២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន **១២**គោលដៅ មនុស្សចំនួន **១០២**នាក់(ស្រី**៨៩**នាក់)។

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង កំពត កោះកុង ក្រចេះ ព្រះវិហារ និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន **៣៣**លើក។

**២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន **១៦៣**នាក់(ស្រី**១៧**នាក់) មាន**១៧**សញ្ជាតិ រួមមានៈ ចិន កូរ៉េខាងត្បូង អាមេរិក អូស្ត្រាលី បារាំង ជប៉ុន ថៃ វៀតណាម ឥណ្ឌូនេស៊ី កាណាដា ម៉ាឡេស៊ី អាឡឺម៉ង់ ហ្វីលីពីន អ៊ីស្រាអែល ឆេក អាហ្វ្រិកខាងត្បូង និងម៉ារ៉ុក។ បានវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញ-ចូលតែមួយចំនួន **១១៣**នាក់(ស្រី**០៩**នាក់)។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្ដាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្ដាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន **១.១៣៣**នាក់។

- **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានផ្សព្វផ្សាយអំពីកម្រងប្រកាសពាក់ព័ន្ធនឹងពលកម្មកុមារទាំង១៣ ដោយក្នុងនោះបានផ្ដោតសំខាន់ទៅលើ ប្រកាសស្ដីពីការហាមប្រាមប្រើប្រាស់ពលកម្មកុមារនៅក្នុងសិប្បកម្មផលិត សុវត្ថិភាពការងារ ការបង្ការនិងការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ជំងឺអេដស៍ គ្រឿងញៀន និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដែលមានម្ចាស់សិប្បកម្ម និងកម្មករចូលរួមសរុបចំនួន **២៥៥**នាក់(ស្រី**១១៤**នាក់)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១៧/២១**ករណី ថយចុះចំនួន **០៤**ករណី ស្មើនឹង **១៩,០៤%** ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្តចំនួន **២០**នាក់(ស្រី **០១**នាក់)។
- សង្គ្រោះជនរងគ្រោះចំនួន **២៣**នាក់(ស្រី **១៦**នាក់) អាយុក្រោម១៥ឆ្នាំ **១២**នាក់ អាយុ១៥-១៧ឆ្នាំ **០២**នាក់ និងអាយុ១៨ឆ្នាំឡើង **០៩**នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **០៤**នាក់ ប្រគល់ឱ្យអន្តោប្រវេសន៍ **០២**នាក់ និងប្រគល់ឱ្យគ្រួសារ **១៧**នាក់) ក្នុងនោះចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **០៥**ករណី/**០៦**ករណី (ថយចុះ **០១**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **០៧**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **០៨**នាក់(ស្រី**០១**នាក់) អាយុក្រោម១៥ឆ្នាំ **០១**នាក់ និងអាយុ១៨ឆ្នាំឡើង **០៧**នាក់ (ប្រគល់ឱ្យអន្តោប្រវេសន៍ **០២**នាក់ និងប្រគល់ឱ្យគ្រួសារ **០៦**នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ(ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៤ | ០៦(០១) | ០៦ |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០២(០០) | ០១ |
| *សរុប* | *០៥ ករណី* | *០៨ នាក់(០១)* | *០៧នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន **១២**ករណី/**១៥**ករណី (ថយចុះ **០៣**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១៣**នាក់ (ស្រី **០១**នាក់)។ សង្គ្រោះជនរងគ្រោះចំនួន **១៥**នាក់(ស្រី**១៥**នាក់) អាយុក្រោម១៥ឆ្នាំ **១១**នាក់ អាយុ១៥-១៧ឆ្នាំ **០២**នាក់ និងអាយុ១៨ឆ្នាំឡើង **០២**នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **០៤**នាក់ និងប្រគល់ឱ្យគ្រួសារ **១១**នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ(ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៤(០៤) | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១១(១១) | ១២ |
| *សរុប* | *១២ ករណី* | *១៥ នាក់(១៥)* | *១៣ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា**

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ** បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសចិនចំនួន **០៣**នាក់(ស្រី) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ។

- **មណ្ឌលសំចតប៉ោយប៉ែត៖**
  - ទទួលពករចំណាកស្រុក ដែលបញ្ជូនត្រឡប់ពីប្រទេសថៃចំនួន**៦៧២**នាក់ (ស្ត្រី **២២៧**នាក់ កុមារា **៤៦**នាក់ កុមារី **២៦**នាក់) បានកំណត់អត្តសញ្ញាណបឋមរកឃើញករណីងាយរងគ្រោះ **០១**នាក់ ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស **០២**នាក់(ប្រុស) ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម និងបានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការ IJM ។

- **កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃ និងវៀតណាមបញ្ជូនត្រឡប់មកវិញចំនួន **៥០**លើក មនុស្សចំនួន **៧០១**នាក់(ស្រី**៣៤៨**នាក់) អនីតិជន **៧២**នាក់ (ស្រី**២៦**នាក់) ក្នុងនោះមាន៖
  - ខេត្តបន្ទាយមានជ័យចំនួន **៣៨**លើក មនុស្ស **៦៧២**នាក់(ស្រី**៣៣៧**នាក់) អនីតិជន **៧២**នាក់ (ស្រី**២៦**នាក់)។
  - ខេត្តស្វាយរៀងចំនួន **០១**លើក មនុស្ស **០៣**នាក់(ស្រី)។
  - ខេត្តកោះកុងចំនួន **១១**លើក មនុស្ស **២៩**នាក់(ស្រី**០៨**នាក់)។

### ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន **០៦**នាក់ (ស្ត្រី **០៥**នាក់) ក្នុងនោះ៖ អង្គការការពារសិទ្ធិកម្ពុជា **០២**នាក់ អង្គការមូលនិធិឋាហារអន្តរជាតិ **០២**នាក់ អង្គការសម្ព័ន្ធចាប់ដៃ **០២**នាក់(ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធម្មទ: **០៤**នាក់ និងករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម **០២**នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្ដុះបណ្ដាល និងសិក្ខាសាលា

#### ក.១. ការងារបណ្ដុះបណ្ដាល

| ល.រ | សកម្មភាពរៀបចំវគ្គបណ្ដុះបណ្ដាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្រី |
|---|---|---|---|---|
| ១ | **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានបើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប ដោយមានការឧបត្ថម្ភគាំទ្រដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM)៖<br>-សហការរៀបចំដោយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តពោធិ៍សាត់<br>-សហការរៀបចំដោយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបាត់ដំបង | <br>០១<br>០១ | <br>៤៨<br>៥៦ | <br>៣៦<br>២៨ |
| ២ | **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានសហការជាមួយអង្គការមេត្រីអន្តរជាតិ (AIM SWAT) បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីយុទ្ធវិធីប្រតិបត្តិការ ដល់មន្ត្រីជំនាញនាយកដ្ឋាន។ | ០១ | ២០ | ០៤ |
| ៣ | **ខេត្តស្វាយរៀង៖** -មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន០៦ បើកវគ្គបណ្ដុះបណ្ដាលដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្ដីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អ ដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្ដីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។<br>-សហការជាមួយអង្គការជំនួយផ្លូវច្បាប់សម្រាប់ស្ត្រីនិងកុមារ បើកវគ្គបណ្ដុះបណ្ដាលស្ដីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ការគ្រប់គ្រងករណី និងប្រព័ន្ធបញ្ជូនបន្ត | ០៧<br>០១ | ១៣២<br>៤៨ | ៧៦<br>២៦ |
| ៤ | **ខេត្តបាត់ដំបង៖** សហការជាមួយអង្គការសាម៉ារីតាន់ភឺស បើកវគ្គបណ្ដុះបណ្ដាលពីរបៀបផ្សព្វផ្សាយបន្តពីចំណាកស្រុកដោយសុវត្ថិភាពដល់អ្នកស្ម័គ្រចិត្តភូមិ និងយុវជនស្ម័គ្រចិត្តក្នុងការផ្សព្វផ្សាយបន្តនូវមេរៀនពីការចំណាកស្រុកដោយសុវត្ថិភាពតាមខ្នងផ្ទះ និងយុវជន តាមសាលារៀន | ០១ | ១៤៧ | ៧៧ |
| ៥ | **ខេត្តព្រះវិហារ៖** ស្នងការដ្ឋាននគរបាលខេត្ត បានបើកវគ្គបណ្ដុះបណ្ដាលស្ដីពីការបង្ការទប់ស្កាត់ការលួចនាំមនុស្សឆ្លងដែនដោយខុសច្បាប់ និងការជួញដូរមនុស្សគ្រប់ទម្រង់ | ០១ | ១០០ | ១១ |
| | **សរុប** | **១៣ លើក** | **៥៥១ នាក់** | **២៥៨ នាក់** |

#### ក.២. សិក្ខាសាលា

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានរៀបចំសិក្ខាសាលា ពិនិត្យ សម្រេចលើសេចក្ដីព្រាងចុងក្រោយផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០២៤-២០២៨) ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ គោលបំណងនៃសិក្ខាសាលា គឺដើម្បី ពិនិត្យ និងសម្រេច ទៅលើខ្លឹមសារនៃផែនការយុទ្ធសាស្ត្រ៥ ដែលបានដាក់ឱ្យពិភាក្សា ក្នុងការធ្វើបច្ចុប្បន្នភាព កែតម្រូវ និងលុបចោល នូវគោលបំណងយុទ្ធសាស្ត្រ និងចង្កោមសកម្មភាពយុទ្ធសាស្ត្រ កាលពីកិច្ចពិភាក្សាកន្លងមក ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សរុបចំនួន **១៦១**នាក់(ស្រី**៦២**នាក់)។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

#### ខ.១.១ កិច្ចប្រជុំក្នុងប្រទេស

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានរៀបចំកិច្ចប្រជុំពិភាក្សា សេចក្តីព្រាងផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេស៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានការអញ្ជើញចូលរួមពីលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និង តំណាងពីអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ចំនួន១៤រូប ។

### ខ.២. ការទទួលជួបពិភាក្សាការងារ

- **ខេត្តកំពង់ឆ្នាំង៖** លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាជាមួយអង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ ដើម្បីសហការអនុវត្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅខេត្តកំពង់ឆ្នាំង ០១លើក។
- **ខេត្តកំពង់ចាម៖** ក្រុមការងារទេសន្តរប្រវេសន៍ការងារ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលជួបពិភាក្សាការងារជាមួយ អ្នកវាយតម្លៃមកពីប្រទេសកាណាដា លើការអនុវត្តគម្រោងចំណាកស្រុកប្រកបដោយសុវត្ថិភាព របស់អង្គការអន្តរជាតិខាងការងារ(ILO) ០១លើក។
- **ខេត្តសៀមរាប៖** លោក **ប៊ីក គីមជុន** នាយករងរដ្ឋបាលសាលាខេត្ត និងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយអង្គការសម្ព័ន្ធចាប់ដៃ ០១លើក ស្តីពីការពង្រឹងកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៧៥**លើក មានអ្នកចូលរួមសរុប **៩៣១**នាក់(ស្រី**៤១៦**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១២**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៤លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **៥៩**លើក។**(ឧបសម្ព័ន្ធ១)**

## IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។

- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមេសា ឆ្នាំ ២០២៤

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដេកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៨. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

៩. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល។

១០. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ...ចន្ទ ៦ កើត...ខែ...ពិសាខ...ឆ្នាំ រោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី...១៣...ខែ...មិថុនា...ឆ្នាំ២០២៤

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៧៥លើក) មនុស្សចំនួន ៩៣១នាក់ (ស្រី ៤១៦នាក់)**

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបិទកិច្ចប្រជុំកម្រិតបច្ចេកទេសពិនិត្យសេចក្តីព្រាងឯកសារស្តីពីទេសន្តរប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា អមវត្តមាន ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ លោកស្រី **គ្រីស្ទីន ផាកូ** នាយិកាអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) សមាសភាពចូលរួមក្នុងកិច្ចប្រជុំរួមមានមកពី ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សរុបចំនួន **២៩**រូប។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- សិក្ខាសាលាពិនិត្យ និងសម្រេច លើសេចក្តីព្រៀងចុងក្រោយ ផែនការ យុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០២៤-២០២៨) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- ប្រជុំទ្វេភាគីរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិវិធិប្រតិបត្តិ បទដ្ឋាន (SOP) សម្រាប់ការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **ឯកឧត្តម ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច នៅសណ្ឋាគារ សុខាល័យ ខេត្តសៀមរាប។<br>- ជាគណៈអធិបតីក្នុងវគ្គផ្សព្វផ្សាយស្តីពី ការកំណត់អត្តសញ្ញាណកុមាររងគ្រោះ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ ដែលរៀបចំឡើងនៅខេត្តបាត់ដំបង ក្រោមជំនួយឧបត្ថម្ភរបស់អង្គការឆាលហ្វាន់ប្រចាំកម្ពុជា សហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួម **៣៦**នាក់។<br>- កិច្ចប្រជុំពិភាក្សា សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់រវាង គ.ជ.ប.ជ និងអង្គការមូលនិធិអេ២១ ស្តីពី កិច្ចសហប្រតិបត្តិការលើការងារបង្ការ ទប់ស្កាត់ និងកំណត់អត្តសញ្ញាណបឋម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស សម្រាប់អនុវត្តក្នុងឆ្នាំ ២០២៤-២០២៦ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១១ច្បាប់ លិខិតចូល ២១ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៦ច្បាប់ លិខិតចូល ១៤ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- លោកប្រធានក្រុមជំនួយកិច្ចការ បានចូលរួមប្រជុំកែសម្រួលមេរៀន ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាសមស្រប។ |

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមប្រជុំទ្វេភាគីរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិវិធិប្រតិបត្តិ បទដ្ឋាន(SOP) សម្រាប់ការគ្រប់គ្រង ករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព **ឯកឧត្តម ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច នៅសណ្ឋាគារ សុខាល័យ ខេត្តសៀមរាប។
  - បានចូលរួមក្នុងសិក្ខាសាលាស្តីពី ការបង្ហាញលទ្ធផល និងអនុសាសន៍ពីការពិគ្រោះយោបល់ជាមុន លើការពិនិត្យគោលការណ៍ណែនាំស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របសម្រាប់ គម្រោងអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ជនរងគ្រោះដែលរួចពីការជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម **ឌិន ប៊ុរី** អគ្គនាយក នៃអគ្គនាយកដ្ឋាន សេវាសង្គមកិច្ច នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ អញ្ជើញពី ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា អគ្គលេខាធិកាដ្ឋាន គជ មណ្ឌលសំចតប៉ោយប៉ែត.ប.ជ. ការិយាល័យ JICA ប្រចាំនៅកម្ពុជា គម្រោង JICA និងអង្គការ IOM សរុប **៣១**រូប នៅសាលប្រជុំសណ្ឋាគារសាន់ & មូន រាជធានីភ្នំពេញ។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**
  - លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់រវាង គ.ជ.ប.ជ និងអង្គការមូលនិធិអេ២១ ស្តីពី កិច្ចសហប្រតិបត្តិការលើការងារបង្ការ ទប់ស្កាត់ និងកំណត់អត្តសញ្ញាណបឋម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស សម្រាប់អនុវត្តក្នុងឆ្នាំ ២០២៤-២០២៦ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
  - លោកអនុប្រធានក្រុម បានចូលរួមធ្វើជាគ្រូឧទេស ក្នុងវគ្គផ្សព្វផ្សាយ ស្តីពីការកំណត់អត្តសញ្ញាណកុមាររងគ្រោះការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទលើកុមារ ដែលបានរៀបចំឡើងនៅសាលប្រជុំស្រុកសំឡូតខេត្តបាត់ដំបង។
  - លោកស្រីអនុប្រធានក្រុម បានចូលរួមសិក្ខាសាលាស្តីពី ការបង្ហាញលទ្ធផល និងអនុសាសន៍ពីការពិគ្រោះយោបល់ជាមុន លើការពិនិត្យគោលការណ៍ណែនាំស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របសម្រាប់ គម្រោងអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ជនរងគ្រោះដែលរួចពីការជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម **ឌិន ប៊ុរី** អគ្គនាយក នៃអគ្គនាយកដ្ឋាន សេវាសង្គមកិច្ច នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ អញ្ជើញពី ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា អគ្គលេខាធិកាដ្ឋាន គជ មណ្ឌលសំច.ប.ជ.តប៉ោយប៉ែត ការិយាល័យ JICA ប្រចាំនៅកម្ពុជា គម្រោងJICA និងអង្គការ IOM នៅសណ្ឋាគារសាន់ & មូន រាជធានីភ្នំពេញ។
- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**
  - ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង បានចូលរួមៈ **១**.កិច្ចប្រជុំរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងកម្ពុជា-ថៃ ស្តីពីការប្រើប្រាស់កម្លាំងពលកម្មពលករកម្ពុជា ទៅធ្វើការក្នុងវិស័យទូកនេសាទ និងកែច្នៃអាហារសមុទ្រនៅប្រទេសថៃ ក្រោមការដឹកនាំដោយ ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ **២**.កិច្ចប្រជុំកម្រិតបច្ចេកទេសសេចក្តីព្រាងឯកសារ ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំរបស់ ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ នៅសណ្ឋាគារសាន់វេភ្នំពេញ។

| | |
|---|---|
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានចូលរួមជាគ្រូបង្គោលវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងករណីនៃមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលគាំទ្រដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍(IOM) នៅខេត្តស្ទឹងត្រែង ០១លើក មានសិក្ខាកាម ៣៦នាក់(ស្រី២៤នាក់) និងខេត្តឧត្តរមានជ័យ ០១លើក សិក្ខាកាម ៣៥នាក់(ស្រី២៤នាក់)។<br>- សម្របសម្រួលរៀបចំសិក្ខាសាលាស្តីពី ការបង្ហាញលទ្ធផលនិងអនុសាសន៍ពីការពិគ្រោះយោបល់ជាមុនសម្រាប់ការពិនិត្យគោលការណ៍ណែនាំស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព ឯកឧត្តម **ឌីន បូរី** អគ្គនាយកសេវាសង្គម នៃក្រសួងសង្គមកិច្ច។<br>- ចូលរួមប្រជុំទ្វេភាគីជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងនីតិវិធីប្រតិបត្តិបទដ្ឋាន(SOP) ស្តីពីការគ្រប់គ្រងករណី និងការធ្វើមាតុភូមិនិវត្តន៍ និងសសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៥៩ លើក អ្នកចូលរួមសរុបចំនួន ៧៦៤ នាក់ (ស្រី ៣៦៨ នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែមីនា និងត្រីមាសទី១ ចំនួន០១លើក អ្នកចូលរួមចំនួន៥៩នាក់ ស្រី៣៩នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែ ចំនួន១២លើក អ្នកចូលរួមចំនួន២៨១នាក់ ស្រី១៤០នាក់។ |
| **ខេត្តសៀមរាប** | - ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំដើម្បីធ្វើការតាមដានត្រួតពិនិត្យ ១០លើក អ្នកចូលរួម ២៥៥នាក់ ស្រី១០០នាក់។<br>- ក្រុមការងារបង្ការទប់ស្កាត់ (មន្ទីរអប់រំ) បានធ្វើការប្រជុំពិភាក្សាជាមួយ អង្គការមូលនិធិអេ២១ លើការផ្សព្វផ្សាយអំពីការស្វែងយល់អំពីការកេងប្រវ័ញ្ចផ្លូវភេទលើយុវជនតាមប្រព័ន្ធអនឡាញ និងការចាញ់បោកគេទៅធ្វើការនៅក្រៅប្រទេស តាមរយៈការចាក់ខ្សែភាពយន្ត នៅតាមសង្គ្រានវិទ្យាល័យ បានចំនួន ០១លើក។<br>- ក្រុមការងារជំនួយការលេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការប្រជុំពិភាក្សា និងរៀបចំសមាសភាពក្រុមការងារជំនួយការ បានចំនួន ០២លើក។ |
| **ខេត្តកោះកុង** | - ប្រធានលេខាធីការដ្ឋានខេត្ត បានដឹកនាំក្រុមការងារលេខាធិការដ្ឋានចូលរួម ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទីសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |
| **ខេត្តស្វាយរៀង** | - បានចូលរួមកិច្ចសន្ទនាសម្រាប់ស្ត្រីក្នុងបណ្តាញការងារអនុវត្តន៍នៅសណ្ឋាគារ សុខាល័យអង្គរ ខេត្តសៀមរាប វត្តមានចូលរួមចំនួណ ៣០នាក់ ស្រី ២៦នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែ និងប្រចាំឆ្នាំ២០២៣ និងលើកទិសដៅបន្ត របស់ គ.ខ.ប.ជ។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាន គ.ខ.ប.ជ នៃគណៈកម្មការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្ត បានរៀបចំរបាយការណ៍ ប្រចាំខែមីនា និងប្រចាំត្រីមាសទី១។ |
| **ខេត្តឧត្តរមានជ័យ** | - ក្រុមការងារទេសន្តរប្រវេសន៍ការងារនៃមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវខេត្តកំពង់ចាម បានទទួលជួបពិភាក្សាការងារជាមួយអ្នកវាយតម្លៃមកពីប្រទេសកាណាដាលើការអនុវត្តគម្រោង ចំណាកស្រុកប្រកបដោយសុវត្ថិភាពរបស់អង្គការអន្តរជាតិខាងការងារ ។ |
| **ខេត្តត្បូងឃ្មុំ** | - ប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំក្រុមការងារលេខាធិការដ្ឋានចូលរួម ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទីសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |

| | |
|---|---|
| ខេត្តស្ទឹងត្រែង | - ប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំក្រុមការងារលេខាធិការដ្ឋានចូលរួម ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទីសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |
| ខេត្តពោធិ៍សាត់ | - សម្របសម្រួលជាមួយ គ.ជ.ប.ជ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដោយមានការឧបត្ថម្ភគាំទ្រដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM)។ |
| ខេត្តបាត់ដំបង | - សម្របសម្រួលជាមួយ គ.ជ.ប.ជ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅស្រុកថ្មគោល ដែលឧបត្ថម្ភគាំទ្រដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM)។<br>- ចូលរួមវគ្គផ្សព្វផ្សាយ ស្តីពីការកំណត់អត្តសញ្ញាណកុមាររងគ្រោះ ការកេងប្រវ័ញ្ច ការរំលោភបំពានផ្លូវភេទលើកុមារ ០១លើក អ្នកចូលរួម ៤៥នាក់ ស្រី២៥នាក់ នៅសាលប្រជុំសាលាស្រុកសំឡូត។<br>- ប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំក្រុមការងារលេខាធិការដ្ឋានចូលរួម ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទីសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។<br>- ចូលរួមជាមួយមណ្ឌលទទួលពលករកំរៀង ចុះផ្សព្វផ្សាយអប់រំស្តីពី "សុវត្ថិភាពទេសន្តប្រវេសក៍ញ្ញាបការការពារខ្លួនពីការឆ្លងមេរោគអេដស៍ និងផលប៉ះពាល់ពីការប្រើប្រាស់គ្រឿងញៀននៅមូលដ្ឋាន" ០៣លើក ដល់ប្រជាពលរដ្ឋសរុប ៥៨នាក់ ស្រី៤៥នាក់ នៅឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។<br>- បានផ្សព្វផ្សាយអំពីការចំណាកស្រុកប្រកបដោយសុវត្ថិភាព បញ្ញាបការការពារខ្លួនពីការឆ្លងមេរោគអេដស៍ ផលប៉ះពាល់ពីការប្រើប្រាស់គ្រឿងញៀន និងការយល់ដឹងអំពីយេនឌ័រដល់ពលករដែលត្រូវបានចាប់បញ្ជូនត្រឡប់ពីប្រទេសថៃ ចូលមណ្ឌលទទួលពលករកំរៀងចំនួន ១៥ លើក ដល់ពលករមានសរុប ៩៤នាក់ ស្រី ៣៨ នាក់ នៅមណ្ឌលទទួលពលករកំរៀង។ |
| ខេត្តក្រចេះ | - ប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំក្រុមការងារលេខាធិការដ្ឋានចូលរួម ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទីសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |
| ខេត្តកំពង់ធំ | - ប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំក្រុមការងារលេខាធិការដ្ឋានចូលរួម ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទីសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |
| ខេត្តកំពង់ស្ពឺ | - ប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំក្រុមការងារលេខាធិការដ្ឋានចូលរួម ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទីសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |
| ខេត្តមណ្ឌលគិរី | - ប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំក្រុមការងារលេខាធិការដ្ឋានចូលរួម ពិធីផ្សព្វផ្សាយរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទីសដៅបន្តឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |